long beach unified school district

**OFFICE OF THE ASSISTANT SUPERINDENT, HIGH SCHOOL**

K-12 Counseling

1515 Hughes Way, Long Beach, CA 90810 • (562) 997-8122 • FAX (562) 997-8301

**សំនួរតែងតែលើកសួរអំពីថ្នាក់គណិតសាស្ត្រ ហៅ Math Bridge ដែលជាថ្នាក់រៀនត្រៀមទុក និង សម្រាប់សិស្សចូលរៀនថ្នាក់ទី 9**

1. **តើខ្ញុំត្រូវការធ្វើអ្វី ដើម្បីចុះឈ្មោះរៀនយកថ្នាក់នេះ?**
   ដើម្បីបើកឆ្លើយបំពេញក្រដាសដាក់ពាក្យ អនឡាញ សម្រាប់កម្មវិធីរៀនរដូវក្តៅ គឺអ្នកនឹងត្រូវការបង្ហាញលេខ ID របស់អ្នកក្នុងនាមជាសិស្ស និង ថ្ងៃខែកំណើតរបស់អ្នក ។ បន្ទាប់ទៅ អ្នកនឹងសុំឱ្យឆ្លើយបំពេញអំពីពត៍មានសម្រាប់ទាក់ទងក្នុងគ្រាអាសន្ន និង ពត៍មានអំពីវេជ្ជមណ្ឌិតរបស់អ្នក ។ ក្រដាសដាក់ពាក្យ អនឡាញ សម្រាប់កម្មវិធីរៀនរដូវក្តៅ គឺអាចស្វែងរកឃើញនៅតាមៈ
   http://parentlbusd.lbschools.net/enrollment

   ក្រដាសដាក់ពាក្យនឹងមានសម្រាប់ប្រើប្រាស់បានផ្តើមនៅថ្ងៃទី7 ខែឧសភា ទៅដល់ពាក់កណ្តាលយប់នៃថ្ងៃទី28 ខែឧសភា ។

2. **តើថ្ងៃខែសម្រាប់កម្មវិធីរៀនរដូវក្តៅ គឺមាននៅពេលណា?**
   ថ្ងៃចន្ទ ទី28 ខែមិថុនា ទៅ ថ្ងៃសុក្រ ទី30 ខែកក្កដា 2021

3. **តើម៉ោងសម្រាប់កម្មវិធីរៀនរដូវក្តៅ គឺនៅពេលណា?**
   វេនទី 1: 7:50 – 10:15 ព្រឹក      វេនទី 2: 10:35 – 1:00 រសៀល

4. **តើវិទ្យាល័យមួយណា ដែលកូនរបស់ខ្ញុំនឹងរៀនជាមួយ បើសិនជាគេចុះឈ្មោះយកថ្នាក់ Math Bridge?**
   កូនរបស់អ្នកនឹងរៀននៅតាមវិទ្យាល័យ ដែលគេចូលរៀនជាមួយក្នុងរដូវស្លឹកឈើធ្លាក់ បើសិនជាថ្នាក់ Math Bridge មានបើកទទួលនៅតាមកន្លែងនោះ ។ បើសិនជាសិស្សកំពុងរៀននៅតាមសាលាជំនាញណាមួយដូចតទៅ (Browning, CAMS, McBride, Renaissance ឬ Sato) គឺគេនឹងបានទទួលកន្លែងដាក់ឱ្យរៀននៅតាមវិទ្យាល័យជាទំហំធំស្ថិតនៅក្បែរផ្ទះ ។

5. **ចុះបើសិនជាកូនរបស់ខ្ញុំនឹងមិនទៅរៀននៅឯវិទ្យាល័យជាទំហំធំណាមួយក្នុងរដូវស្លឹកឈើធ្លាក់ តើគេនៅតែអាចចូលរួមបានទេ?**
   ពិតណាស់! កូនរបស់អ្នកនៅតែអាចចុះឈ្មោះរៀនយកថ្នាក់ Math Bridge បាន ។ គេនឹងរៀននៅតាមវិទ្យាល័យជាទំហំធំស្ថិតនៅក្បែរផ្ទះយោងតាមអាសយដ្ឋានផ្ទះ ។

6. **តើកូនរបស់ខ្ញុំនឹងបានពិន្ទុ ក្រេឌិត សម្រាប់ថ្នាក់គណិតសាស្ត្រនេះ មែនទេ?**
   សិស្សនឹងបានទទួលពិន្ទុ ក្រេឌិត ជារបៀបជ្រើសរើសសម្រាប់ថ្នាក់គណិតសាស្ត្រ ។ ដោយមូលហេតុថា ថ្នាក់នេះជាថ្នាក់រៀនត្រៀមទុក គឺវាផ្តល់ពិន្ទុ ក្រេឌិត សម្រាប់តែការជ្រើសរើសប៉ុណ្ណោះ ។

7. **តើវាមានប្រយោជន៍អ្វីទៅសម្រាប់ការរៀនយកថ្នាក់នេះនៅរដូវក្តៅ?**
   ប្រយោជន៍មកពីថ្នាក់នេះ គឺការយល់ដឹងទុកជាមុនអំពីមេរៀន និង ការទទួលចំណេះជាមូលដ្ឋានសម្រាប់បង្កើនលទ្ធផលជោគជ័យនៅពេលរៀនយកថ្នាក់គណិតសាស្ត្រមែនទែនក្នុងឆ្នាំសិក្សា ។ សិស្សនឹងក៏បានទទួលពិន្ទុ ក្រេឌិត ដែរជារបៀបជ្រើសរើសសម្រាប់ថ្នាក់នេះ ។

8. **ចុះបើសិនជាខ្ញុំមានគម្រោងធ្វើដំណើរកំសាន្តនៅពេលថ្នាក់រដូវក្តៅកំពុងតែបើក តើខ្ញុំនៅតែអាចចុះឈ្មោះបានទេ?**
   បើសិនជាអ្នកមានគម្រោងធ្វើដំណើរកំសាន្តនៅពេលថ្នាក់រដូវក្តៅកំពុងតែបើក (ថ្ងៃទី28 ខែមិថុនា ទៅ ថ្ងៃទី30 ខែកក្កដា) គឺមានការស្នើសុំមិនឱ្យអ្នកចុះឈ្មោះយកថ្នាក់រៀនរដូវក្តៅ ។ ច្បាប់ដាក់កម្រិតយ៉ាងតឹងមកថា សិស្សអាចឈប់ពីថ្នាក់បានត្រឹមតែចំនួន 4 ថ្ងៃប៉ុណ្ណោះ ដើម្បើទទួលជា

ពិន្ទុជាប់ថ្នាក់បាន ។ បើសិនជាអ្នកមានគម្រោង ដែលធ្វើឱ្យសិស្សរបស់អ្នកនឹងឈប់ពីថ្នាក់លើសជាង 4 ថ្ងៃរៀន គឺមានន័យថា មិនគួរចុះឈ្មោះយកថ្នាក់រៀនរដូវក្តៅទេ ។

9. **តើច្បាប់ទាក់ទងការកត់ចំនួនថ្ងៃចូលរៀន និង ការចូលរៀនមិនទាន់ពេលក្នុងថ្នាក់រដូវក្តៅ គឺមានដល់កម្រិតណាទៅ?**
ការចូលរៀនរាល់ថ្ងៃ គឺតម្រូវធ្វើឱ្យបានជាកម្រិតយ៉ាងតិចបំផុត 85% សម្រាប់ទទួលពិន្ទុ ក្រេឌិត បាន ។ សិស្សនឹងមិនបានទទួលពិន្ទុ ក្រេឌិតទេ បើសិនជាគេឈប់ពីថ្នាក់លើសជាងចំនួន 10 ម៉ោង (4 ថ្ងៃ) ។ ការឈប់ពីថ្នាក់មួយលើក គឺស្មើចំនួន 2.5 ម៉ោង និង ការចូលរៀនមិនទាន់ពេលមួយលើក គឺស្មើការឈប់ពីថ្នាក់ចំនួន 30 នាទី ។ បន្ទាប់ពីសិស្សបានឈប់ពីថ្នាក់ដល់ចំនួន 10 ម៉ោងហើយ គឺឈ្មោះរបស់គេនឹងទម្លាក់ចេញពីថ្នាក់ ។

10. **សព្វថ្ងៃនេះ សិស្សរបស់ខ្ញុំកំពុងរៀនថ្នាក់គណិតសាស្ត្រជាកម្រិត Math 8, តើថ្នាក់មួយណា ដែលគេគួរចុះឈ្មោះរៀនយកនៅពេលរដូវក្តៅ?**
Pre-Algebra

11. **សព្វថ្ងៃនេះ សិស្សរបស់ខ្ញុំកំពុងរៀនថ្នាក់គណិតសាស្ត្រជាកម្រិត Algebra I, តើថ្នាក់មួយណា ដែលគេគួរចុះឈ្មោះរៀនយកនៅពេលរដូវក្តៅ?**
Pre-Geometry

12. **សព្វថ្ងៃនេះ សិស្សរបស់ខ្ញុំកំពុងរៀនថ្នាក់គណិតសាស្ត្រជាកម្រិត Geometry, តើថ្នាក់មួយណា ដែលគេគួរចុះឈ្មោះរៀនយកនៅពេលរដូវក្តៅ?**
Pre-Algebra 2

13. **ចុះបើសិនជាសិស្សរបស់ខ្ញុំនឹងចូលរៀនថ្នាក់រដូវក្តៅនៅឯសាលា Millikan ឬ Wilson, តើគេនឹងស្លៀកពាក់ជាឯកសណ្ឋានស្របច្បាប់តម្រូវ មែនទេ?**
ពិតណាស់! នឹងមានការតម្រូវឱ្យស្លៀកពាក់ជាឯកសណ្ឋាននៅតាមសាលារៀនរដូវក្តៅ ។

14. **តើអាហារថ្ងៃត្រង់ ដែលមិនបាច់បង់លុយ ឬ ចុះបន្ថយតម្លៃនឹងមានសម្រាប់ទទួលដែរ ឬ ទេក្នុងកម្មវិធីរៀនរដូវក្តៅ?**
ពិតណាស់! អាហារថ្ងៃត្រង់នឹងចែកផ្តល់សម្រាប់សិស្ស ដែលមានសិទ្ធិទទួល ។

15. **ចុះបើសិនជាខ្ញុំមិនអាចឆ្លើយបំពេញក្រដាសដាក់ពាក្យ អនឡាញ ឱ្យទាន់ ថ្ងៃទី30 ខែឧសភា, តើខ្ញុំនៅតែអាចចុះឈ្មោះយកថ្នាក់បានទេ?**
យើងសុំជម្រុញដល់សិស្ស និង មាតាបិតាទាំងអស់ឱ្យឆ្លើយបំពេញក្រដាស់ដាក់ពាក្យ អនឡាញ ទាន់ថ្ងៃខែកំណត់ ។ បើសិនជាក្រដាសឆ្លើយបំពេញមិនបានសព្វគ្រប់ទេ គឺអ្នកនឹងរង់ចាំទាល់តែដល់ដើមសប្តាហ៍ពេលថ្នាក់រដូវក្តៅចាប់ផ្តើមឡើងសិន ដើម្បីព្យាយាមចុះឈ្មោះយកថ្នាក់ ។ ទំរាំតែដល់ពេលនោះ គឺថ្នាក់ទាំងអស់នឹងពេញអស់ទៅហើយ ។

16. **តើមានថ្នាក់អ្វីផ្សេងទៀតទេសម្រាប់សិស្សរបស់ខ្ញុំ ដែលនឹងចូលរៀនថ្នាក់ទី9 អាចចុះឈ្មោះយកបាន ក្រៅតែពីថ្នាក់ Math Bridge?**
នឹងមានថ្នាក់ជាបន្ថែមផ្សេងៗសម្រាប់បើករៀនយកពិន្ទុ ក្រេឌិត ដូចដើមវិញ ។ ប៉ុន្តែ ថ្នាក់ទាំងអស់នោះ គឺបើកទទួលតែនៅតាមកន្លែងមួយចំនួនប៉ុណ្ណោះ ។ សូមឆែកមើលនៅតាម គេហទំព័រសម្រាប់កម្មវិធីរៀនរដូវក្តៅ ដើម្បីចំណាំអំពីប្រភេទថ្នាក់ ដែលនឹងបើកទទួលនៅតាមសាលារៀននិមួយៗ ។ ក្រៅតែពីថ្នាក់សម្រាប់ពិន្ទុ ក្រេឌិត វិទ្យាល័យ គឺសាលារៀននិមួយៗក៏នឹងបើកជាថ្នាក់ផ្សេងៗទៀតផងដែរ ដែលមិនផ្តល់ជាពិន្ទុ ក្រេឌិត សម្រាប់តែការរៀនបង្កើនចំណេះ ។ សូមឆែកមើលនៅតាម គេហទំព័រសម្រាប់កម្មវិធីរៀនរដូវក្តៅ ដើម្បីចំណាំអំពីប្រភេទថ្នាក់ទាំងអស់នោះ ។ ការចុះឈ្មោះរៀនយកថ្នាក់មិនផ្តល់ជាពិន្ទុ ក្រេឌិត គឺនឹងធ្វើនៅតាមវិទ្យាល័យ ។ សូមទាក់ទងទៅកាន់វិទ្យាល័យផ្ទាល់ ។